តេឡេក្រាម ឯកសារមន្ត្រីសាធារណ:

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.៨០.១០.....សហវ.......

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកែសម្រួលកម្រៃសេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និង សំណង់ និង វិធាននិងនីតិវិធីនៃការអនុវត្តចំណូលនិងចំណាយថវិកាសម្រាប់ការចារ ចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី

| ឧបនាយករដ្ឋមន្ត្រី | ឧបនាយករដ្ឋមន្ត្រី |
|---|---|
| រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ |

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia



ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ២៩១ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីនីតិវិធីគ្រប់គ្រង និងអនុវត្តថវិកាសម្រាប់យុទ្ធនាការជំរុញការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៣៥៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញប្រកាសរួមលេខ ៦៤៩ សហវ.ប្រក ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការផ្តល់ថវិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណង កំណត់អំពីការកែសម្រួលកម្រងសេវាសាធារណៈនៃការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធ និងកំណត់វិធាននិងនីតិវិធីនៃការអនុវត្តចំណូលនិងចំណាយថវិកាសម្រាប់ការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ដើម្បីជានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការអនុវត្តចំណូលនិងចំណាយថវិកា។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## ជំពូកទី ២

## ការកែសម្រួលកម្រងសេវាសាធារណៈ

**ប្រការ៣.-**

ត្រូវបានកែសម្រួលកម្រងសេវាសាធារណៈ ត្រង់ចំណុច "១- ការចុះបញ្ជីដីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធ" នៃ II- សេវាសុរិយោដី និងភូមិសាស្ត្រ ស្ថិតក្នុងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ ៣៥៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដូចខាងក្រោម ៖

| លេខរៀងចំនួនសេវា | បរិយាយ | | តម្លៃសេវា (រៀល ក្នុង ១ ម៉ែត្រការ៉េ) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| | ១ | ការចុះបញ្ជីដីធ្លីលើកដំបូង ដែលមានលក្ខណៈជាប្រព័ន្ធ | | | អចិន្ត្រៃយ៍ | |
| | | ក.ដីផលិតកម្មកសិកម្ម | | | | |
| | - | ដីផលិតកម្មកសិកម្មក្នុងឃុំក្រៅទីរួមស្រុក | ៣ | ១០០ថ្ងៃ | | កម្រៃត្រូវបង់ទាបបំផុត ១ ០០០ រៀល |
| | - | ដីផលិតកម្មកសិកម្មក្នុងឃុំទីរួមស្រុក | ៤ | ១០០ថ្ងៃ | | |
| | - | ដីផលិតកម្មកសិកម្មក្នុងក្រុងប្រភេទ ខ | ៦ | ១០០ថ្ងៃ | | |
| | - | ដីផលិតកម្មកសិកម្មក្នុងក្រុងប្រភេទ ក | ១២ | ១០០ថ្ងៃ | | |
| | - | ដីផលិតកម្មកសិកម្មនៅរាជធានីភ្នំពេញ | ២៥០ | ១០០ថ្ងៃ | | កម្រៃត្រូវបង់ទាបបំផុត ៥ ០០០ រៀល |
| | | ខ.ដីលំនៅឋាន ឬដីសាងសង់ | | | | |
| | - | ដីលំនៅឋាន ឬដីសាងសង់ក្នុងឃុំក្រៅទីរួមស្រុក | ២០ | ១០០ថ្ងៃ | | |
| | - | ដីលំនៅឋាន ឬដីសាងសង់ក្នុងឃុំទីរួមស្រុក | ៣០ | ១០០ថ្ងៃ | | |
| | - | ដីលំនៅឋាន ឬដីសាងសង់ក្នុងក្រុងប្រភេទ ខ | ៤០ | ១០០ថ្ងៃ | | |
| | - | ដីលំនៅឋាន ឬដីសាងសង់ក្នុងក្រុងប្រភទ ក | ២៥០ | ១០០ថ្ងៃ | | |
| | - | ដីលំនៅឋាន ឬដីសាងសង់នៅរាជធានីភ្នំពេញ | ៥០០ | ១០០ថ្ងៃ | | |

កំណត់សម្គាល់ :

- ពាក្យ "ក្រុងប្រភេទ ក" សំដៅដល់ ក្រុងដែលបានបង្កើតដោយអនុក្រឹត្យមុនឆ្នាំ២០២១។
- ពាក្យ "ក្រុងប្រភេទ ខ" សំដៅដល់ ក្រុងដែលបានបង្កើតដោយអនុក្រឹត្យចាប់ពីឆ្នាំ២០២១។

**ប្រការ៤.-**

ដីរបស់គ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលមានបណ្ណសមធម៌ និងគ្រួសារងាយរងហានិភ័យដែលមានបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យចេញដោយក្រសួងផែនការ ព្រមទាំងដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ ដីគ្រឹះស្ថានសាធារណៈរដ្ឋបាល និងគរុភណ្ឌជាដីរបស់វត្ត រដ្ឋទទួលបន្ទុកសោហ៊ុយចំណាយចំនួន ៧៦ ០០០ (ចិតសិបប្រាំមួយពាន់) រៀល ក្នុង ១ បណ្ណ សម្រាប់ការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធ។

**ប្រការ៥.-**

ការបង់កម្រៃសេវាដូចមានចែងក្នុងប្រការ ៣ ខាងលើ ត្រូវអនុវត្តនៅពេលម្ចាស់កម្មសិទ្ធិទៅទទួលយកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដោយការប្រមូលកម្រៃសេវាសុរិយោដីនៃការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធនេះ ជាសមត្ថកិច្ចរបស់មន្ត្រីសុរិយោដី។

## ជំពូកទី ៣
## នីតិវិធីអនុវត្តផ្នែកចំណូល

**ប្រការ៦.-**

ចំណូលប្រមូលបានពីប្រភេទសេវាសាធារណៈកែសម្រួលថ្មី ដែលចែងក្នុងប្រការ ៣ នៃប្រកាសអន្តរក្រសួងនេះ ត្រូវអនុវត្តដូចខាងក្រោម ៖

- ត្រូវបង់ និងកត់ត្រាទាំងស្រុងជាចំណូលរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែលជាចំណូលថវិកាថ្នាក់ជាតិ ដោយអនុវត្តចាប់ពីកាលបរិច្ឆេទដែលប្រកាសអន្តរក្រសួងនេះចូលជាធរមាន រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៧។ ចំណូលប្រមូលបាននេះ ត្រូវបានចោះក្រវិលសម្រាប់រ៉ាប់រងសោហ៊ុយចំណាយលើការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធ។
- មិនអនុញ្ញាតឱ្យដកប្រាក់រង្វាន់លើកទឹកចិត្តពីចំណូលប្រមូលបានពីកម្រៃសេវាសុរិយោដីនៃការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធ ដែលបានកំណត់ដោយប្រកាសរួមលេខ ៦៤៩ សហវ.ប្រក ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៧ ឡើយ ។
- ត្រូវបង់ និងកត់ត្រាជាចំណូលពីការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធរបស់រដ្ឋបាលរាជធានី ខេត្តសាមី តាមយន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៨ តទៅ។ ចំណូលប្រមូលបាននេះ ត្រូវបានបន្តចោះក្រវិលសម្រាប់រ៉ាប់រងសោហ៊ុយចំណាយលើការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធ។

## ជំពូកទី ៤
## មុខសញ្ញាចំណាយ និងគោលរបប

**ប្រការ៧.-**

គោលរបប សម្រាប់ចំណាយលើការងារចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ត្រូវបានកំណត់ចំនួន ៧៦ ០០០ (ចិតសិបប្រាំមួយពាន់) រៀល ក្នុង ១ បណ្ណ។ មុខសញ្ញាចំណាយ និងគោលរបប ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី ១ នៃប្រកាសនេះ ។

## ជំពូកទី ៥
## វិធាននៃការគ្រោងថវិកា

**ប្រការ៨.-**

សម្រាប់មុខសញ្ញាចំណាយដែលមានចែងក្នុងប្រការ ៧ ថវិកាត្រូវគ្រោង អនុវត្ត និងកត់ត្រាក្នុងជំពូក ៦៥ គណនី ៦៥០៧ អនុគណនី ៦៥០៧២ "ការចូលរួមក្នុងការអនុវត្តគម្រោងមូលនិធិទ្រទ្រង់ថវិកា"។

## ជំពូកទី ៦
## នីតិវិធីអនុវត្តផ្នែកចំណាយ

**ប្រការ៩.-**

ចំណាយសម្រាប់ការងារចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

- ដើម្បីឱ្យការបើកផ្តល់សាច់ប្រាក់មុនលើកដំបូង បានឆាប់រហ័ស ទាន់ពេលវេលា នាដើមឆ្នាំអនុវត្តថវិកា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចរៀបចំលិខិតស្នើសុំបើកប្រាក់លើកដំបូងចំនួន ២០ ០០០ ០០០ ០០០ (ម្ភៃប៊ីលាន) រៀល តាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន ឱ្យបានមុនដំណាច់ខែវិច្ឆិកា មុនឆ្នាំអនុវត្តថវិកា សម្រាប់ចំណាយការងារចុះបញ្ជីដីធ្លីលើកដំបូងដែលលក្ខណៈជាប្រព័ន្ធ ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលមានបណ្ណសមធម៌ និងគ្រួសារងាយរងហានិភ័យដែលមានបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យ ចេញដោយក្រសួងផែនការ, ដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ ដីគ្រឹះស្ថានសាធារណៈរដ្ឋបាល និងគុកណ្ឌាជាដីរបស់វត្ត ព្រមទាំងសម្រាប់ការងារចុះបញ្ជីដីធ្លីដោយប្រើប្រាស់ចំណូលដែលបានពីកម្រៃសេវាសុរិយោដីនៃការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធ រួចបញ្ជូនមកអ្នកត្រួតពិនិត្យថវិកា និងគណនេយ្យករសាធារណៈ។ គំរូលិខិតស្នើសុំបើកប្រាក់លើកដំបូងមានកំណត់ជាឧបសម្ព័ន្ធទី ២ នៃប្រកាសនេះ ។
- ការបើកផ្តល់ថវិកាសម្រាប់ចំណាយបន្តបន្ទាប់ទៀត ត្រូវធ្វើឡើងក្រោមរូបភាពជាការបំពេញឡើងវិញនូវថវិកាដែលបានចំណាយជាក់ស្តែង ទៅតាមទំហំទឹកប្រាក់នៃអាណត្តិនិយ័តកម្មស្នើសុំទូទាត់ រហូតដល់ដំណាច់ឆ្នាំថវិកា។ ចំពោះការទូទាត់ចំណាយដោយត្រូវប្រើប្រាស់ថវិកាដែលប្រមូលបានពីកម្រៃសេវាសុរិយោដីនៃការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធ និងតាមចំនួនបណ្ណនៃក្បាលដីសម្រេចបាន ត្រូវបានអនុញ្ញាតឱ្យបោះផ្សាយអាណត្តិនិយ័តកម្មក្នុងទំហំមិនឱ្យលើសពីទំហំចំណូលថវិកាដែលបានប្រមូល និងបន្ទាប់ពីបានបង់ចូលគណនីទោលរតនាគាររួច។ គំរូលិខិតស្នើសុំថវិកាជាបន្តបន្ទាប់ មានកំណត់ក្នុងឧបសម្ព័ន្ធទី ៣ នៃប្រកាសនេះ ។

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំស្នើសុំទូទាត់ចំណាយសម្រាប់ការងារចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ឱ្យបានត្រឹមត្រូវ និងឆាប់រហ័ស ដើម្បីធានានិរន្តរភាពនៃចំណាយសម្រាប់អនុវត្តសកម្មភាពដែលបានគ្រោងទុកឱ្យបានទាន់ពេលវេលា ដោយមិនត្រូវរង់ចាំឱ្យអស់សាច់ប្រាក់ពីបេឡាឡើយ។
- ថវិកាសម្រាប់ការងារចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ត្រូវគ្រប់គ្រងដោយអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ រដ្ឋទេយ្យករបុរេប្រទាន/រដ្ឋទេយ្យករបុរេប្រទានរង ត្រូវទុកដាក់ថែរក្សានូវសាច់ប្រាក់ដែលខ្លួនបានទទួលពីគណនេយ្យករសាធារណៈ ព្រមទាំងទុកដាក់ថែរក្សាលិខិតយុត្តិការ កាន់កាប់បញ្ជីបេឡាដោយឡែកសម្រាប់តាមដានចំណូល ចំណាយ និងប្រាក់សម្រាប់ការងារចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ។
- ក្នុងដំណាក់កាលអន្តរកាល នៅពេលមុខងារស្កេនលិខិតយុត្តិការចំណាយពុំទាន់អាចអនុវត្តក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) បាននៅឡើយ អាណត្តិនិយ័តកម្មស្នើសុំទូទាត់ ត្រូវភ្ជាប់មកជាមួយតែរបាយការណ៍ចំណាយថវិកាច្បាស់លាស់ និងរបាយការណ៍លទ្ធផលនៃការចែកបណ្ណ ដែលបង្ហាញអំពីទិន្នន័យ ជាអាទិ៍ លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ កាលបរិច្ឆេទ និងទីកន្លែងនៃការចេញបណ្ណ ។ល។ ចំពោះលិខិតយុត្តិការចំណាយដែលជាច្បាប់ដើម ត្រូវរក្សាទុកនៅអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ សម្រាប់ជាកម្មវត្ថុនៃការធ្វើអធិការកិច្ច និងសវនកម្មតាមក្រោយ។ គំរូរបាយការណ៍ចំណាយថវិកា និងរបាយការណ៍លទ្ធផលនៃការចែកបណ្ណ មានភ្ជាប់ជាឧបសម្ព័ន្ធទី ៤ នៃប្រកាសនេះ ។
- នៅពេលមុខងារស្កេនលិខិតយុត្តិការចំណាយ អាចអនុវត្តក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) លិខិតយុត្តិការចំណាយដែលជាច្បាប់ដើមត្រូវរក្សាទុកនៅអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ដោយត្រូវស្កេនបញ្ចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដើម្បីជាមូលដ្ឋានក្នុងការពិនិត្យដោយអ្នកត្រួតពិនិត្យថវិកា គណនេយ្យករសាធារណៈ និងការធ្វើសវនកម្មដោយសវនករ ឬ អធិការកិច្ចដោយមន្ត្រីអធិការកិច្ច។
- អ្នកត្រួតពិនិត្យថវិកានិងគណនេយ្យករសាធារណៈ ត្រូវពិនិត្យផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃអាណត្តិនិយ័តកម្ម របាយការណ៍ចំណាយថវិកា និងរបាយការណ៍លទ្ធផលនៃការចែកបណ្ណ របស់អាណាប័កដើម្បីផ្តល់ទិដ្ឋាការ និងការទូទាត់ចំណាយ ។
- ក្នុងករណីពិនិត្យឃើញថា អាណត្តិនិយ័តកម្ម របាយការណ៍ចំណាយថវិកា និងរបាយការណ៍ពាក់ព័ន្ធ ពុំទាន់មានលក្ខណៈត្រឹមត្រូវ និងមិនអនុលោមតាមបទប្បញ្ញត្តិនៃប្រកាសនេះ អ្នកត្រួត-ពិនិត្យថវិកា និងគណនេយ្យករសាធារណៈ មានសិទ្ធិស្នើសុំការបញ្ជាក់បំភ្លឺពីអាណាប័ក ឬស្នើសុំឯកសារបន្ថែម ឬមិនផ្តល់ទិដ្ឋាការ ឬមិនធ្វើការទូទាត់ជូន ។ ក្នុងករណីដែលអ្នកត្រួតពិនិត្យថវិកា ឬ/និងគណនេយ្យករសាធារណៈ បដិសេធមិនផ្តល់ទិដ្ឋាការ ឬមិនធ្វើការទូទាត់ជូនដោយសារពុំបានទទួលការបញ្ជាក់ ឬឯកសារបន្ថែមត្រឹមត្រូវ និងគ្រប់គ្រាន់ពីអាណាប័ក អ្នកត្រួតពិនិត្យថវិកា ឬ/និងគណនេយ្យករសាធារណៈ ត្រូវបញ្ជូនអាណត្តិនិយ័តកម្មនោះ ត្រលប់ទៅអាណាប័កវិញ

ដោយមានការបញ្ជាក់អំពីចំណុចខ្វះខាត។ ក្រោយពីកែតម្រូវលើអាណត្តិនិយ័តកម្ម ឬលិខិតយុត្តិការចំណាយរួច អាណាប័កត្រូវផ្ញើជូនអ្នកត្រួតពិនិត្យថវិកាសាជាថ្មី ដើម្បីពិនិត្យ និងបញ្ជូនបន្តមកគណនេយ្យករសាធារណៈ ។

**ប្រការ១០.-**

ក្នុងការអនុវត្តចំណាយថវិកា រដ្ឋទេយ្យករបុរេប្រទាន/រដ្ឋទេយ្យករបុរេប្រទានរង ត្រូវខិតខំប្រមូលលិខិតយុត្តិការចំណាយជូនអាណាប័ក ដើម្បីទូទាត់និងជម្រះបញ្ជីចំណាយនេះឱ្យបានទាន់ក្នុងឆ្នាំថវិកា យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្ត ។

## ជំពូកទី ៧
## ការត្រួតពិនិត្យចំណាយសម្រាប់ការងារចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី

### ផ្នែកទី ១
### គោលការណ៍ទូទៅ

**ប្រការ១១.-**

ចំណាយថវិកាសម្រាប់ការងារចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធ នៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យនៃអាណាប័ករបស់ខ្លួន ។ ទន្ទឹមនេះ ចំណាយនេះត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យផ្ទៀងផ្ទាត់និងត្រួតពិនិត្យនៅនឹងកន្លែង ពីអគ្គាធិការដ្ឋាន និងអាជ្ញាធរមានសមត្ថកិច្ច ស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មិនត្រូវរក្សាទុកសាច់ប្រាក់ចុងឆ្នាំសម្រាប់ចំណាយនៅឆ្នាំបន្ទាប់ឡើយ។ ក្នុងករណីមានសាច់ប្រាក់នៅសល់ចុងឆ្នាំ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបង់ចូលគណនីចរន្តរបស់រតនាគារថ្នាក់កណ្តាលនៅធនាគារឱ្យបានមុនដំណាច់ឆ្នាំថវិកានីមួយៗ ដោយរៀបចំសំណើបង់សាច់ប្រាក់សល់ពីការបើកផ្តល់មុន ដោយបញ្ជាក់ខ្លឹមសារច្បាស់លាស់អំពីការទូទាត់ជម្រះចំណាយសម្រាប់ការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី និងភ្ជាប់ជាមួយនូវប្រកាសឥណទាន ឬ បណ្ណបង់ប្រាក់ ឬ របាយការណ៍ធនាគារ។ ក្នុងករណីមិនទាន់មានការបង់សាច់ប្រាក់នៅសល់ឱ្យទាន់នាដំណាច់ឆ្នាំអនុវត្តថវិកា គណនេយ្យករសាធារណៈ នឹងមិនបើកផ្តល់សាច់ប្រាក់ចំណាយសម្រាប់ការងារចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លីសម្រាប់ឆ្នាំបន្ទាប់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នោះទេ។ ទន្ទឹមនេះ ដើម្បីធានាបាននូវនិរន្តរភាពនៃចំណាយលើការងារចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំលិខិតស្នើសុំបើកប្រាក់លើកដំបូងតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន ឱ្យបានឆាប់រហ័ស នាដំណាច់ឆ្នាំមុនអនុវត្តថវិកា ដើម្បីអាចបើកផ្តល់សាច់ប្រាក់មុនលើកដំបូង បានទាន់ពេលវេលានាដើមឆ្នាំអនុវត្តថវិកា។

### ផ្នែកទី ២
### ការត្រួតពិនិត្យលើលិខិតយុត្តិការ

**ប្រការ១២.-**

អាណាប័កមានភារកិច្ចត្រួតពិនិត្យដូចតទៅ ៖

- អាណាប័កតម្រូវឱ្យរដ្ឋទេយ្យករបុរេប្រទាន/រដ្ឋទេយ្យករបុរេប្រទានរង ផ្តល់នូវបញ្ជីបេឡាប្រចាំខែ និងប្រចាំឆ្នាំព្រមទាំងរបាយការណ៍លទ្ធផលនៃការអនុវត្តចំណាយ និងកំណត់ហេតុត្រួតពិនិត្យផ្ទាល់នៅនឹងកន្លែងលើការងារនេះ
- អាណាប័កត្រូវពិនិត្យលិខិតយុត្តិការចំណាយដែលផ្តល់ដោយរដ្ឋទេយ្យករបុរេប្រទាន/រដ្ឋទេយ្យករបុរេប្រទានរង និងត្រូវធានាថា ឯកសារទាំងឡាយត្រឹមត្រូវពិតប្រាកដ ព្រមទាំងពិនិត្យថា ការទូទាត់ប្រព្រឹត្តទៅតាមគោលរបបដែលមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ។

**ប្រការ១៣.-**

អ្នកត្រួតពិនិត្យថវិកាមានភារកិច្ចត្រួតពិនិត្យអាណត្តិនិយ័តកម្ម របាយការណ៍ចំណាយថវិកា របាយ-ការណ៍លទ្ធផលនៃការបែកបណ្ណ និងបញ្ជីបេឡាសម្រាប់ការងារចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លីដែលផ្តល់ដោយអាណាប័ក និងផ្តល់ទិដ្ឋាការ ។

**ប្រការ១៤.-**

គណនេយ្យករសាធារណៈ មានភារកិច្ចត្រួតពិនិត្យអាណត្តិនិយ័តកម្ម របាយការណ៍ចំណាយថវិកា របាយការណ៍លទ្ធផលនៃការបែកបណ្ណ សម្រាប់ការងារចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី បញ្ជីបេឡាសម្រាប់ការងារចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី និងផ្តល់ការទូទាត់ ។

## ផ្នែកទី ៣
## ការត្រួតពិនិត្យដល់ទីកន្លែង

**ប្រការ១៥.-**

អាណាប័ក អ្នកត្រួតពិនិត្យថវិកា គណនេយ្យករសាធារណៈ អគ្គាធិការ និងមន្ត្រីនៃស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត អាចធ្វើការត្រួតពិនិត្យ ឬ ផ្ទៀងផ្ទាត់នៅនឹងកន្លែងដោយផ្ទាល់លើការងារគ្រប់គ្រងថវិកាសម្រាប់ការងារចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ។ ការត្រួតពិនិត្យត្រូវប្រព្រឹត្តទៅដោយពុំប្រាប់ឱ្យដឹងជាមុន។ អាណាប័ក អាចចាត់តាំងតំណាង ឬ អង្គភាពនៅក្រោមឱវាទដើម្បីធ្វើការត្រួតពិនិត្យផ្ទាល់នៅនឹងកន្លែង ។

ការត្រួតពិនិត្យខាងលើត្រូវធ្វើលើចំណុចជាអាទិ៍ដូចខាងក្រោម ៖

- របាយការណ៍ចំណាយថវិកា
- របាយការណ៍លទ្ធផលនៃការអនុវត្តការងារ
- អត្ថិភាពចំណាយ
- ការបញ្ឈប់និងផ្តល់ទិដ្ឋាការលើបញ្ជីទាំងឡាយ
- ការរៀបចំបញ្ជីបេឡាសម្រាប់ការងារចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី
- លិខិតយុត្តិការផ្សេងៗដែលមានការពាក់ព័ន្ធទៅនឹងការរៀបចំ និងកិច្ចដំណើរការចំណាយលើការងារចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ។

ក្រៅពីស្ថាប័នមានសមត្ថកិច្ចដែលកំណត់ដោយច្បាប់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមាននីតិ-សម្បទាក្នុងការចាត់ឱ្យមានការត្រួតពិនិត្យលើចំណាយសម្រាប់ការងារចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈ

ជាប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី តាមសំណើរបស់អ្នកត្រួតពិនិត្យថវិកា និង/ឬគណនេយ្យករសាធារណៈ។ ការត្រួតពិនិត្យនេះត្រូវមានសមាសភាពមកពីអ្នកត្រួតពិនិត្យថវិកានិងគណនេយ្យករសាធារណៈ ដែលមានលិខិតបញ្ជាបេសកកម្មត្រឹមត្រូវ ។

**ប្រការ១៦.-**

ការត្រួតពិនិត្យដោយអាណាប័កត្រូវធ្វើឱ្យបានញឹកញាប់និងជាប្រចាំ ។ ជាគោលការណ៍ ការត្រួតពិនិត្យលើរបាយការណ៍ចំណាយថវិកា និងអត្ថិភាពចំណាយ គឺត្រូវធ្វើក្នុង ១ (មួយ) ត្រីមាសម្តង ។ ដោយឡែករបាយការណ៍លទ្ធផលនៃការអនុវត្តការងារ ត្រូវធ្វើឡើងក្នុង ១ (មួយ) ឆមាសម្តង ។

ការត្រួតពិនិត្យរបស់អ្នកត្រួតពិនិត្យថវិកា និងគណនេយ្យករសាធារណៈ ត្រូវធ្វើឡើងដោយឈរលើគោលការណ៍គ្រប់គ្រងហានិភ័យតាមការចាត់តាំងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

រាល់ពេលត្រួតពិនិត្យមួយលើកៗ ត្រូវមានរបាយការណ៍ឬកំណត់ហេតុត្រឹមត្រូវច្បាស់លាស់ ដែលក្នុងនោះត្រូវកត់សម្គាល់នូវកិច្ចការដែលបានពិនិត្យឃើញ ។ ឯកសារទាំងនោះត្រូវផ្តល់ឱ្យរដ្ឋទេយ្យករបុរេប្រទាន/រដ្ឋទេយ្យករបុរេប្រទានរងធ្វើការកត់សម្គាល់និងផ្តល់នូវចម្លើយ ហើយត្រូវធ្វើត្រលប់ទៅភ្នាក់ងារត្រួតពិនិត្យ និងអាណាប័កវិញ ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**ប្រការ១៧.-**

បណ្ណដែលបានចេញ ហើយដែលម្ចាស់មិនទាន់មកទទួល និងមិនទាន់បង់កម្រៃសេវាសុរិយោដីនៃការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធ នៅមុនពេលប្រកាសនេះចូលជាធរមាន ត្រូវអនុវត្តការបង់កម្រៃសេវាសុរិយោដីនៃការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធ ស្របតាមប្រការ ៣ នៃប្រកាសនេះ ។

**ប្រការ១៨.-**

នៅពេលប្រកាសអន្តរក្រសួងនេះចូលជាធរមាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ **អាចរៀបចំលិខិតស្នើសុំបើកប្រាក់លើកដំបូងឆ្នាំ២០២៤ ចំនួន ២០ ០០០ ០០០ ០០០ (ម្ភៃប៊ីលាន) រៀល** តាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន សម្រាប់ចំណាយការងារចុះបញ្ជីដីធ្លីលើកដំបូងដែលលក្ខណៈជាប្រព័ន្ធ ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលមានបណ្ណសមធម៌ និងគ្រួសារងាយរងហានិភ័យដែលមានបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យ ចេញដោយក្រសួងផែនការ, ដីសាធារណៈរបស់រដ្ឋ, ដីឯកជនរបស់រដ្ឋ ដីគ្រឹះស្ថានសាធារណៈរដ្ឋបាល និងគរុភណ្ឌជាដីរបស់វត្ត ព្រមទាំងសម្រាប់ការងារចុះបញ្ជីដីធ្លីដោយប្រើប្រាស់ចំណូលដែលបានពីកម្រៃសេវាសុរិយោដីនៃការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធ រួចបញ្ជូនមកអ្នកត្រួតពិនិត្យថវិកា និងគណនេយ្យករសាធារណៈ។ គំរូលិខិតស្នើសុំបើកប្រាក់លើកដំបូងមានកំណត់ជាឧបសម្ព័ន្ធទី ២ នៃប្រកាសនេះ ។

**ប្រការ១៩.-**

ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៨ ចំណាយលើការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធ ដោយប្រើប្រាស់ចំណូលដែលប្រមូលបានដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចមានចែងក្នុងប្រការ ៦ នឹងត្រូវកំណត់តាមវិធាន និងនីតិវិធីដោយឡែក។ ចំពោះសោហ៊ុយចំណាយសម្រាប់រ៉ាប់រងការចុះបញ្ជីដីធ្លីលើកដំបូង

ដែលមានលក្ខណៈជាប្រព័ន្ធលើប្រភេទដីដូចមានកំណត់ក្នុងប្រការ ៤ ដែលជាបន្ទុករបស់ថវិកាថ្នាក់ជាតិ នឹងត្រូវអនុវត្តតាមវិធាន និងនីតិវិធីដែលត្រូវធ្វើបច្ចុប្បន្នកម្មតាមស្ថានភាពជាក់ស្តែង។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**ប្រការ២០.-**

ប្រកាសអន្តរក្រសួងលេខ ១៣០ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០២៤ ស្តីពីបែបបទ និងនីតិវិធីចំណាយថវិកាសម្រាប់ការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ត្រូវទុកជានិរាករណ៍។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ២១.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ អង្គារ ៣រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**សាយ សំអាល់**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ២១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ